# សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្បទារបស់ នួន ជា និងវិសាលភាពសំណុំរឿង ០០២
# ថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១៣
# មជ្ឈមណ្ឌលឯកសារកម្ពុជា

ឌី សុជាតា

នៅព្រឹកថ្ងៃទី២៩ ខែមិនា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការខ្លីមួយស្តីពីការប្រកាសសេចក្តីសម្រេចភ្លាមៗ ទាក់ទងនឹងបញ្ហាចំនួនពីរ ។ សេចក្តីសម្រេចទីមួយទាក់ទងនឹង សម្បទារបស់ជនជាប់ចោទ នួន ជា និងទីពីរទាក់ទងនឹងវិសាលភាពនៃសំណុំរឿង ០០២ ដែលចំណាយរយៈពេលប្រហែល២០នាទី និងមានប្រជាជនមកពីខេត្តកំពង់ចាម ប្រហែល២៥០នាក់បានចូលរួមស្តាប់ការប្រកាសសេចក្តីសម្រេចនេះ ។

សេចក្តីសម្រេចទីមួយដែលទាក់ទងនឹងសម្បទារបស់ជនជាប់ចោទ នួន ជា បានធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានទទួលរបាយការណ៍របស់អ្នកជំនាញពីររូប គឺសាស្ត្រាចារ្យ ចន ខាំប៊ែល, អ្នកជំនាញផ្នែកមនុស្សចាស់ និងវេជ្ជបណ្ឌិត ស៊ីណា ហ្វាសែល, អ្នកជំនាញផ្នែកវិកលវិទ្យា ។ ក្រោយពេលទទួលបានរបាយការណ៍របស់អ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូង បានបើកសវនាការមួយនៅថ្ងៃទី២៥ ខែមិនា ឆ្នាំ២០១៣ ដើម្បីទុកលទ្ធភាពឲ្យភាគីទាំងអស់ អាចសួរដេញដោលអ្នកជំនាញទាំងពីររូបទាក់ទងនឹងសម្បទារបស់ជនជាប់ចោទ នួន ជា ក្នុងការចូលរួមសវនាការ ។ ដោយផ្អែកលើរបាយការណ៍ និងការស្តាប់សវនាការសួរដេញដោលអ្នកជំនាញ អង្គជំនុំជម្រះសាលាដំបូង បានចេញសេចក្តីសម្រេចថា ជនជាប់ចោទ នួន ជា មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះបានលើកឡើងថា បើទោះបីជាជនជាប់ចោទ នួន ជា មានវ័យចាស់ជរា និងទន់ខ្សោយ ប៉ុន្តែរបាយការណ៍ និងសក្ខីកម្មរបស់អ្នកជំនាញវេជ្ជសាស្ត្រ ដែលចាត់តាំងដោយតុលាការបានបញ្ជាក់ថា នួន ជា នៅតែអាចចូលរួមនីតិវិធីសវនាការប្រកបដោយអត្ថន័យ ។

ចំណែកសេចក្តីសម្រេចទីពីរទាក់ទងនឹងការបំបែកសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងសម្រេចបន្តបំបែកកិច្ចដំណើរការនីតិវិធីសវនាការដដែល គឺសំណុំរឿង០០២/០១ ដោយកំណត់នូវវិសាលភាពជំនុំជម្រះនៃដំណាក់កាលដំបូងនេះ ត្រឹមតែការជម្លៀសប្រជាជនដំណាក់កាលទី១ និងដំណាក់កាលទី២ និងបូកបន្ថែមទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ។

សេចក្តីសម្រេចដែលបានប្រកាសនៅព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៣ គឺជាសេចក្តីសម្រេចសង្ខេបផ្ទាល់មាត់ប៉ុណ្ណោះ ។ អង្គជំនុំជម្រះសាលាដំបូង នឹងចេញសេចក្តីសម្រេចជាលាយលក្ខអក្សរ ដោយមានសំអាងហេតុគ្រប់គ្រាន់នៅពេលសមស្របខាងមុខ ។

សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនាពេលនេះ ហាក់បីដូចជាពុំបានឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី កាលពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ទេ ។ អង្គជំនុំជម្រះសាលាដំបូងពុំបានឆ្លើយតបនឹងសំណើសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលស្នើសុំឲ្យដាក់បញ្ចូលអង្គហេតុទាក់ទងនឹងមន្ទីរសន្តិសុខ ស-២១ ចូលទៅក្នុងសំណុំរឿង០០២/០១ ។ ចំណែកសំណើរបស់មេធាវីការពារក្តីដែលស្នើសុំឲ្យមានការជំនុំជម្រះ លើសំណុំរឿង០០២ទាំងមូលក៏ពុំត្រូវបានទទួលយកដោយអង្គជំនុំជម្រះដែរ ។ បន្ទាប់ពីការបញ្ចប់កិច្ចដំណើការនីតិវិធីសវនាការសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងនឹងចេញសាលក្រមមួយផ្តន្ទាទោសប្រសិនបើរកឃើញថា ជនជាប់ចោទពិតជាមានពិរុទ្ធភាព ។

-ចប់-